ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍
BUDDHISM FOR DEVELOPMENT
ភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
Tel: 012 67 74 98 /097 73 43 063
E-mail: bfdpvh@bfdkhmer.org

---

# របាយការណ៍សង្ខេប
# ការចុះប្រមូលព័ត៌មាន និងទិន្នន័យ

(ចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ ០៧ ខែកក្កដា ឆ្នាំ២០១៥)

## ១. សាវតានៃគម្រោង

GFA ដែលជាក្រុមហ៊ុននាំមុខគេមួយ ជារួមមានក្រុមហ៊ុន Sequa ប្រទេសអាល្លឺម៉ង់ និងអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD) ជាដៃគូ និងក្រុមហ៊ុនម៉ៅការមួយចំនួន, រួមបញ្ចូលទាំងអង្គការអភិវឌ្ឍន៍ប្រទេសស៊ុយអ៊ែត "HELVETAS" និងសណ្ឋាគារនៅប្រទេសស្វីស បានបង្កើតសមាគមមួយសម្រាប់អនុវត្តនូវជំនាញរបស់គម្រោងអភិវឌ្ឍន៍ជំនាញកម្ពុជា (Skill Development Program (SDP)) តំណាងឲ្យទីភ្នាក់ងារស្វីសដើម្បីការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ ។ SDP ត្រូវបានរំពឹងថា នឹងចូលរួមចំណែកដល់ការពង្រឹកសកម្មភាពអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស (TVET) មួយដែលបង្កើននូវដំណើរការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការធ្វើឱ្យប្រសើរឡើងនូវឱកាសការងារដល់យុវជនក្រីក្រដែលជួបការលំបាកនៅតាមទីជនបទ ។ អង្គការ ពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ នេះត្រូវបានគេជ្រើសរើសជាដៃគូក្នុងស្រុក និងវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលទទួលខុសត្រូវក្នុងការចុះស្រង់ព័ត៌មាន និងទិន្នន័យនៅក្នុងខេត្តគោលដៅទាំង៣ មានខេត្តព្រះវិហារ, ស្ទឹងត្រែង និងក្រចេះ។

## ២. គោលបំណងនៃការស្រង់ព័ត៌មាន

គោលបំណងនៃការស្រង់ព័ត៌មាន គឺដើម្បីវាស់វែងលើសូចនាករនៃកម្មវិធីអភិវឌ្ឍន៍ជំនាញ ដែលព័ត៌មានទាំងនោះមានទាំងគុណភាព និងបរិមាណទាក់ទងនឹងស្ថានភាពនាពេលបច្ចុប្បន្ន ដែលនឹងមានការផ្លាស់ប្តូរនាពេលអនាគត

## ៣. វិសាលភាពនៃកិច្ចការ

អង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ជួយសម្រួលដល់ការងារមួយចំនួនដើម្បីប្រមូលព័ត៌មាននៃកម្មវិធីអភិវឌ្ឍន៍ជំនាញ (Skill Development Program ហៅកាត់ថា SDP) ក្នុងខេត្តព្រះវិហារ ។ ភារកិច្ចចម្បងនោះ គឺជ្រើសរើសបុគ្គលិកចុះសម្ភាសន៍ចំនួន១២នាក់ សម្រាប់ចុះសម្ភាសន៍ផ្នែកទី១ **(ហៅថា Component 1)** និងបុគ្គលិក៣នាក់ទៀតសម្រាប់ចុះសម្ភាសន៍ផ្នែកទី៣ **(ហៅថា Component 3)** និងមានមន្ត្រីសម្របសម្រួលចំនួន០២រូប ដើម្បីទំនាក់ទំនងការងារក្នុងខេត្ត ។

## ៤. ការជ្រើសរើសអ្នកសំរបសំរួលថ្នាក់ខេត្ត និងបុគ្គលិកចុះសម្ភាសន៍

មន្ត្រីទំនាក់ទំនងប្រចាំខេត្ត ត្រូវបានតែងតាំងដោយអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ដើម្បីសម្របសម្រួលការងារ ជាមួយអាជ្ញាធរមូលដ្ឋាន (ភូមិ ឃុំ ស្រុក ខេត្ត ព្រមទាំងស្ថាប័នពាក់ព័ន្ធជុំវិញខេត្ត) ដើម្បីជូនដំណឹង និងសុំកិច្ចសហការគ្នា មុនពេល ក្នុងអំឡុងពេលប្រមូលទិន្នន័យ ។

អ្នកសម្របសម្រួលថ្នាក់ខេត្ត មានតួនាទីពិនិត្យមើល, បញ្ជាក់, អនុម័ត និងសហការគ្នាជាមួយអាជ្ញាធរមូលដ្ឋាន និងជួយផ្តល់ព័ត៌មានទៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងមន្ត្រីទំនាក់ទំនង ដែលបញ្ជាក់អំពីការចូលរួមរបស់អ្នកទទួលផលតាមភូមិគោលដៅ បន្ទាប់ពីប្រជុំជាមួយនឹងប្រធានភូមិ និងដំណើរការនៃការជ្រើសរើសអ្នកផ្តល់ព័ត៌មាន ។ អ្នកសម្របសម្រួលថ្នាក់ខេត្ត ក៏បានទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីពិនិត្យមើលស្ថានភាពផ្លូវក្នុងការធ្វើដំណើរទៅតំបន់គោលដៅផងដែរ មុនពេលធ្វើដំណើរចុះទៅសម្ភាសន៍ ប្រសិនបើស្ថានភាពផ្លូវនោះ មិនអាចធ្វើដំណើរបានទេ អ្នកសម្របសម្រួលថ្នាក់ខេត្ត នឹងរាយការណ៍ទៅក្រុមការងារ ដែលមកពី CDRI ដើម្បីស្នើសុំរៀបចំផែនការឡើងវិញ ។

អ្នកសម្របសម្រួលថ្នាក់ខេត្ត ទទួលខុសត្រូវក្នុងការប្រមូលនូវបញ្ជីឈ្មោះម្ចាស់សិប្បកម្ម/អាជីវកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមក្នុងក្រុងជុំវិញខេត្តព្រះវិហារ ដើម្បីសម្ភាសន៍ និងបញ្ជាក់ ថាតើពួកគេអាចអនុញ្ញាតឲ្យសម្ភាសន៍បាន ឬមិនបាន ។

- **សមាសភាគទី១** (Component 1) មានបុគ្គលិកចុះសម្ភាសន៍ចំនួន១២នាក់ (ស្ត្រី៣នាក់) ដែលបានជ្រើសរើសចេញពីមន្ទីរកិច្ចការនារីចំនួន ៣នាក់, មន្ទីរអប់រំ ៣នាក់ និង៦នាក់ផ្សេងទៀត ត្រូវបានជ្រើសរើសតាមរយៈសេចក្តីប្រកាសជាសាធារណៈ។ បុគ្គលិកចុះសម្ភាសន៍ មានតួនាទីចូលរួមក្នុងវគ្គបណ្តុះបណ្តាលធ្វើឡើងដោយបុគ្គលិកមកពីវិទ្យាស្ថានបណ្តុះ បណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងមានកម្រងសំណួរនៃការប្រមូលទិន្នន័យដែលរៀបចំដោយ CDRI ផងដែរ ។

- **សមាសភាគទី៣** (Component 3) មានបុគ្គលិកចុះសម្ភាសន៍ចំនួន៣នាក់ ដែលបានជ្រើសរើសចេញពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងខេត្ត ។ ពួកគេមានតួនាទីចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយ CDRI មុនពេលចុះប្រមូលទិន្នន័យតាមមូលដ្ឋាន ។

## ៥. ការសម្របសម្រួល និងវគ្គបណ្តុះបណ្តាល

### <u>៥.១. អ្នកសម្របសម្រួលថ្នាក់ខេត្ត</u>

អ្នកសម្របសម្រួលថ្នាក់ខេត្ត ត្រូវបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលចំនួនកន្លះថ្ងៃ ដែលរៀបចំនៅខេត្តស្ទឹងត្រែង និងសម្របសម្រួលដោយក្រុម CDRI មកពីក្រុងភ្នំពេញ ។ ការចូលរួមកន្លះថ្ងៃនេះ គឺយើងជជែកគ្នាអំពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកផ្តល់សម្ភាសន៍ (Interviewees) មានអាយុចាប់១៥ឆ្នាំទៅ៣៥ឆ្នាំ ជាគ្រួសារក្រីក្រប្រភេទ១ ប្រភេទ២ និងក្រីក្របំផុតក្នុងមូលដ្ឋាន ។

### <u>៥.២. *សមាសភាគទី១* (component 1)</u>

បុគ្គលិកចុះសម្ភាសន៍ចំនួន១២នាក់ ទៅចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល៤ថ្ងៃ ដែលរៀបចំនៅខេត្តស្ទឹងត្រែង សម្របសម្រួលដោយបុគ្គលិកមកពី CDRI ។ នៅថ្ងៃទីបួននៃវគ្គបណ្តុះបណ្តាលនេះ ត្រូវបានបែងចែកជាពីរ

ផ្នែក៖ ទី១ ត្រៀមសំណួរសម្រាប់ចុះសម្ភាសន៍តាមផ្ទះ និងទី២ គឺផ្តោតទៅលើការបណ្តុះបណ្តាលការងារ ។ គោលបំណងនៃការធ្វើតេស្តសាកល្បង ដើម្បីវាយតម្លៃសមត្ថភាពរបស់បុគ្គលិកទាំងអស់មុនពេលចុះអនុវត្តការងារតាមខេត្តរៀងខ្លួន ។ ការវាយតំលៃសមត្ថភាពបុគ្គលិកនេះ ត្រូវបានធ្វើឡើងដោយក្រុមការងារ CDRI និងតំណាងគម្រោងអភិវឌ្ឍន៍ជំនាញកម្ពុជា (SDP) ។

បន្ទាប់ពីបានណែនាំកម្រងសំណួរ និងបានធ្វើតេស្តលើកម្រងសំណួររួចមក សិក្ខាកាមទាំងអស់ (៣៦នាក់មកពីខេត្តទាំង៣៖ ព្រះវិហារ, ស្ទឹងត្រែង និងក្រចេះ) បានបំបែកតាមខេត្តរៀងៗខ្លួន ដូចជាសិក្ខាកាមមកពីព្រះវិហារត្រូវបានចាត់ឱ្យទៅសាកល្បងនៅក្នុងភូមិកងដីស ស្ថិតនៅក្នុងស្ទឹងត្រែង, ក្រុមមកពីខេត្តក្រចេះ ត្រូវបានគេចាត់ឱ្យទៅសាកល្បងនៅក្នុងភូមិកាំពួន ក្នុងស្រុកសេសាន ក្នុងខេត្តស្ទឹងត្រែង ចំណែកក្រុមស្ទឹងត្រែង ត្រូវបានគេចាត់ឱ្យទៅសាកល្បងនៅក្នុងភូមិសាមឃួយ ស្រុកសេសាន ដែលជាកន្លែងដែលអ្នកភូមិភាគច្រើននិយាយភាសាឡាវ ។

ក្នុងឱកាសនោះ ពួកគេបានជួបលំបាកស្តាប់ សម្រាប់អ្នកមកពីខេត្តក្រចេះ និងព្រះវិហារ មិនអាចយល់នូវការនិយាយរបស់ពួកគេនិយាយមួយចំនួន ។ បន្ទាប់ពីធ្វើតេស្តសាកល្បង ពួកគេបានលើកយកបញ្ហាប្រឈមមួយចំនួនដែលបានរកឃើញក្នុងអំឡុងពេលចុះសម្ភាសន៍តាមភូមិ៖ 1)- អ្នកសម្ភាសន៍ភាគច្រើន អាចនិយាយបានតែភាសាខ្មែរ ឬគ្មាននរណាម្នាក់អាចនិយាយភាសាជនជាតិភាគតិចបាន ។ ឧទាហរណ៍: អ្នកផ្តល់ព័ត៌មានក្នុងភូមិកាំពួន ពួកគាត់និយាយភាសាឡាវបានយ៉ាងស្ទាត់ជំនាញ គាត់យល់ភាសាខ្មែរបានតិចតួចណាស់ បើមិនមានអ្នកជួយបកប្រែបន្ថែមគឺមិនអាចប្រមូលព័ត៌មានបានគ្រប់គ្រាន់ឡើយ ។

### ៥.៣. សមាសភាគទី៣ (component 3)

បុគ្គលិកចុះសម្ភាសន៍ចំនួន៣នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលរយៈពេល៣ថ្ងៃ នៅទីក្រុងភ្នំពេញ ដែលរៀបចំ និងសម្របសម្រួលដោយក្រុមការងារ CDRI ។ វគ្គបណ្តុះបណ្តាលនេះ បានពន្យល់បន្ថែមអំពីវិធីសាស្ត្រក្នុងការអនុវត្ត និងប្រមូលព័ត៌មានតាមសហគ្រាសខ្នាតតូចនិងមធ្យមក្នុងខេត្ត ។ ការជ្រើសរើសអ្នកផ្តល់បទសម្ភាសន៍ គឺជាម្ចាស់អាជីវកម្ម/សហគ្រាសខ្នតតូចនិងមធ្យម និងអ្នកហាត់ការ/កូនជាង ដោយប្រើកម្រងសំណួរ និងសំណួរសាកល្បងដែលបានសិក្សាក្នុងអំឡុងវគ្គណ្តុះបណ្តាលនៅទីក្រុងភ្នំពេញរយៈពេល៣ថ្ងៃ ។

## ៦.ការជ្រើសរើសភូមិគោលដៅ

ដោយផ្អែកលើទិន្នន័យ និងភូមិសាស្ត្រដែលបានផ្តល់ឱ្យដោយគម្រោងអភិវឌ្ឍន៍ជំនាញកម្ពុជា (SDP) ហើយជាភូមិឃុំស្រុកមានជនក្រីក្រ និងក្រីក្របំផុត; ចំនួនភាគរយខ្ពស់នៃជនជាតិភាគតិច; មនុស្សជួបគុណវិបត្តិ និងតំបន់គោលដៅស្ថិតនៅក្បែរប្រាសាទព្រះវិហារ ។ ដំណើរការនៃការជ្រើសរើស គឺផ្អែកលើកិច្ចប្រជុំ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៥ នៅការិយាល័យ CDRI, ដោយតាមខេត្តនីមួយៗ គួរតែជ្រើស ៣ស្រុក ៣ឃុំ និង៣ភូមិ ដែលមានភូមិសរុបទាំងអស់ចំនួន៣០ភូមិ និងជ្រើសរើសម្ចាស់អាជីវកម្ម/សិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមចំនួន៩៦ ក្នុងខេត្តទាំង៣ (៤៨ មានម្ចាស់ជាបុរស និង៤៨ មានម្ចាស់ជាស្ត្រី) និងមានកូនជាងមកហាត់ការងារចំនួន៩៦នាក់ (៤៨ ជាបុរស និងស្ត្រីចំនួន៤៨នាក់ មានអាយុចាប់ពី១៥ឆ្នាំ ទៅ៣០ឆ្នាំ) ដែលត្រូវជ្រើសរើសយកមកសម្ភាសន៍ក្នុងសមាសភាគទី៣ (component 3) ។ ដោយឡែកក្នុងខេត្តព្រះវិហារត្រូវជ្រើសរើស១០ភូមិនៃស្រុកទាំង៣ និងម្ចាស់អាជីវកម្ម/សិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមចំនួន៣២កន្លែង ។

### ៦.១. វិធីសាស្ត្រនៃការជ្រើសរើសអ្នកផ្តល់បទសម្ភាសន៍ (Interviewees)

ជ្រើសរើសដោយចន្លោះៗ (Random) ដោយប្រើប្រាស់បញ្ជីស្នាមដែលមានស្រាប់ ផ្តល់ដោយលោកមេភូមិ និងការចុះដោយផ្ទាល់ជួបម្ចាស់រោងសិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមនៅក្នុងខេត្ត ។

❖ <u>ភូមិគោលដៅដែលត្រូវជ្រើសរើសសម្រាប់សម្ភាសន៍សម្រាប់សមាសភាគទី១ (Component 1)</u>

| ល.រ | ស្រុក | ឃុំ | ល.រ | ឈ្មោះភូមិ | ចំនួនអ្នកផ្តល់សម្ភាសន៍ | អាយុចន្លោះពី |
|---|---|---|---|---|---|---|
| ១ | ជាំក្សាន្ត | កន្ទួត | ១ | ស្រែអែមខាងត្បូង | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | | ២ | សុខសែនជ័យ | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | | ៣ | កន្ទួត | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| ២ | ត្បែងមានជ័យ | ប្រមេរ | ៤ | បុះធំ | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | | ៥ | ស្រែព្រាង | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | | ៦ | ប្រមេរ | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| ៣ | ជ័យសែន | តស៊ូ | ៧ | តស៊ូ | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | ស្អាង | ៨ | គោក | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | ផ្អា | ៩ | ផ្អា | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| | | ពុទ្រា | ១០ | ពើក | ២០នាក់ (ប:១០ ស:១០) | ១៥ទៅ៣៥ឆ្នាំ |
| សរុប | ៣ស្រុក | ៦ឃុំ | | ១០ភូមិ | ២០០នាក់ (ប:១០០ ស:១០០ | |

❖ <u>សិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមសម្រាប់សមាសភាគទី៣ (Component 3)</u>

| ល.រ | ប្រភេទសហគ្រាសខ្នាតតូចនិងមធ្យម | ចំនួនទីតាំង | ចំនួនអ្នកផ្តល់បទសម្ភាសន៍ | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| 1 | ជួសជុលម៉ូតូ | 4 | 8 | 4 |
| 2 | ហាងអ៊ុតសក់/កាត់សក់/ធ្វើក្រចក | 4 | 8 | 4 |
| 3 | ហាងជួសជុលទូរស័ព្ទ/កំព្យូទ័រ | 3 | 6 | 3 |
| 4 | តម្បាញ/កាត់សម្លៀកបំពាក់ | 6 | 12 | 6 |
| 5 | សិប្បកម្មតុទូ | 4 | 8 | 4 |
| 6 | សំណង់ | 3 | 6 | 3 |
| 7 | សិប្បកម្មផ្សារដែក | 3 | 6 | 3 |
| 8 | សិប្បកម្មចម្លាក់ | 5 | 10 | 5 |
| | សរុប | 32 | 64 | 32 |

## ៧. ការប្រមូលទិន្នន័យ

### ៧.១. សមាសភាគទី១ (Component 1)

កាលវិភាគនៃការចុះស្រង់ទិន្នន័យនិងព័ត៌មាន បានចាប់ផ្ដើមពីថ្ងៃទី២៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ដែលរៀបចំដោយអ្នកសម្របសម្រួលថ្នាក់ខេត្ត ។ តាមក្រុមនិមួយៗដែលគ្នចំនួន៤នាក់នោះ ត្រូវបានដឹកនាំដោយបុគ្គលិក CDRI មួយនាក់ ហើយក្នុងក្រុមនិមួយៗត្រូវចុះសម្ភាសន៍ឲ្យបានមនុស្សចំនួន២០នាក់ ដែលរស់នៅក្នុងភូមិគោលដៅ និងមានអាយុ/ភេទ/ក្រីក្រ/ស្ត្រីជាមេគ្រួសារ/ជនពិការជាដើម (ទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយក្រុមការងារ) ។

ដោយសារតែមានភូមិសាស្ត្រ; ប្រជាសាស្ត្រ និងបរិយាកាសដ៏ល្អ ក្រុមទាំង៣នៅខេត្តព្រះវិហារបានបញ្ចប់ការចុះប្រមូលទិន្នន័យនិងព័ត៌មានតាមមូលដ្ឋាន គឺខុសពីការវាយតម្លៃ (ព្រះវិហារ យល់បាន ៦០%) របស់ក្រុមការងារ CDRI ក្នុងវគ្គបណ្ដុះបណ្ដាលនៅខេត្តស្ទឹងត្រែង ។ ផ្លូវចូលទៅភូមិគោលដៅអាចធ្វើដំណើរបាន អាជ្ញាធរមូលដ្ឋានសហការបានល្អ ប្ដេជ្ញាចិត្តប្រឹងប្រែងអនុវត្តការងារ និងមានទំនុកចិត្តលើអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ ។

### ៧.២. សមាសភាគទី៣ (Component 3)

ក្រុមនេះមានសមាជិក៣នាក់ ជ្រើសរើសដោយអង្គការពុទ្ធសាសនា ដើម្បី អភិវឌ្ឍន៍ (ពដអ) និងដឹកនាំដោយក្រុមការងារមកពី CDRI ត្រូវបំពេញការងាររយៈពេល៦ថ្ងៃ ដោយចាប់ផ្ដើមពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៥ ដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ ។ ពួកគេត្រូវចុះសម្ភាសន៍ម្ចាស់អាជីវកម្ម/សហគ្រាសខ្នាតតូច ដូចជាម្ចាស់ហាងជួសជុលរថយន្ត និងម៉ូតូ, ហាងកាត់សម្លៀកបំពាក់, សំអាងការ, សិប្បកម្មផ្សារដែក/កាត់កញ្ចក់, ជួសជុលទូរស័ព្ទ, សិប្បកម្មនំប៉ុងសំណង់...។ល។

ក្រុមការងារបានចុះជួបសម្ភាសន៍តាមសហគ្រាសខ្នាតតូចនិងមធ្យមចំនួន ៣២កន្លែង ដែលមានម្ចាស់សហគ្រាសផ្នែកបុរស១៦នាក់ និងកូនជាងជាបុរស១៦នាក់ និងម្ចាស់សហគ្រាសផ្នែកស្ត្រី១៦នាក់ និងកូនជាងជាស្ត្រីចំនួន១៦នាក់ សរុប៦៤នាក់ ។

### ៧.៣. លទ្ធផលពីការស្រង់ព័ត៌មាន

- **សមាសភាគទី១** (Component 1)
    1. អ្នកផ្ដល់សម្ភាសន៍ ២០០នាក់ (ប្រុស ១០០ និងស្រី១០០នាក់)
    2. ត្រូវការជំនាញ (ជួសជុលម៉ូតូ, ជួសជុលម៉ាស៊ីនធុនតូច (ម៉ាហ្សូតនិងសាំង) សំអាងការ, ជួសជុលទូរស័ព្ទ....។ល។

- **សមាសភាគទី៣** (Component 3)
    1. អ្នកផ្ដល់សម្ភាសន៍ ៦៤នាក់ ស្មើនឹង ៣២កន្លែង
        a) ម្ចាស់សិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមជាបុរស១៦នាក់ និងកូនជាងជាបុរស១៦នាក់
        b) ម្ចាស់សិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យមជាស្ត្រី ១៦នាក់ និងកូនជាងជាស្ត្រី ១៦នាក់
    2. តម្រូវការជំនាញបន្ថែមដើម្បីបង្កើនប្រាក់ចំណូល (ជំនាញដែលពួកគេកំពុងបំរើការនៅសហគ្រាសបច្ចុប្បន្ន)

## ៨. បញ្ហាជួបប្រទះ

### ៨.១. អាជ្ញាធរមូលដ្ឋាន

- ដោយរដូវនេះ ជារដូវដាំដុះស្រូវ អ្នកភូមិទាំងអស់ គឺជាប់រវល់ខ្លាំងណាស់នៅក្នុងការងារស្រែចំការ ជាពិសេស យុវជនដែលមានអាយុចន្លោះពី១៥ ទៅ៣០ឆ្នាំ ត្រូវជួយការងារឪពុកម្តាយរបស់ពួកគេ ដូច្នេះអាជ្ញាធរមូលដ្ឋាន លោកប្រធានភូមិ ពិបាកក្នុងការរៀបចំ ឬណាត់ជួបដើម្បីរង់ចាំផ្តល់បទសម្ភាសន៍ ហើយម៉្យាងទៀតលោក ប្រធានភូមិខ្លួនឯងផ្ទាល់ ក៏ជាប់រវល់ធ្វើស្រែចំការដែរ ។

### ៨.២. សិប្បកម្ម/សហគ្រាសខ្នាតតូចនិងមធ្យម

- នៅក្នុងទីរួមខេត្តព្រះវិហារ ពុំមានសហគ្រាសខ្នាតតូចនិងមធ្យមតាមតម្រូវការរបស់ SDC និង CDRI ក្នុងការ ប្រមូលទិន្នន័យ ដូច្នេះសិប្បកម្ម/សហគ្រាសខ្នាតតូចត្រូវបានជ្រើសរើសបន្ថែមតាមស្ថានភាពជាក់ស្តែងអាចរក បានតាមមូលដ្ឋាន ។ តាមផែនការក្នុងខេត្តព្រះវិហារត្រូវជ្រើសរើសយក៤៨កន្លែង ដោយយកម្ចាស់អាជីវកម្ម ជាបុរសចំនួន២៤ និងម្ចាស់ជាស្ត្រី២៤នាក់ ប៉ុន្តែមិនអាចរកបាន ភាគច្រើនតាមរោងសិប្បកម្មឬសហគ្រាស ខ្នាតតូច មានតែកម្មករឬបុគ្គលិកបំរើការ ពោលគឺពុំមានយុវជន/បុគ្គលណាមួយមកហាត់ការដើម្បីទទួលយក ចំណេះដឹងទៅប្រកបមុខរបរផ្ទាល់ខ្លួនឡើយ ។

### ៨.៣. ការកំណត់អាយុបុរសនិងស្ត្រីក្នុងការផ្តល់បទសម្ភាសន៍

- ក្នុងការចុះប្រមូលព័ត៌មាន ជាពិសេសបុរសដែលបានកំណត់អាយុពី១៥ឆ្នាំទៅ៣០ឆ្នាំ គឺពិបាករក ដោយសារ តែពួកគេជាប់រវល់ការងារ ។

## ៩. ដំណោះស្រាយ

- ក្រុមការងារបានពិភាក្សាគ្នាអំពីបញ្ហានេះ ដោយបានព្រមព្រៀងតម្លើងអាយុចាប់ពីពី១៥ឆ្នាំ ទៅ៣៥ឆ្នាំ ប៉ុន្តែ ត្រូវរក្សាទុក ៨០% ដែលមានអាយុចាប់ពី១៥ឆ្នាំ ទៅ៣០ឆ្នាំដដែល ។

## ១០.សេចក្តីសន្និដ្ឋាន

- វិធីសាស្ត្រប្រមូលទិន្នន័យ ជាគោលបំណងសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងតំបន់ ដើម្បីកាត់បន្ថយការចំណាកស្រុក និងលើកកម្ពស់ឲ្យមានការចូលរួមរបស់សហគមន៍។
- ការផ្តល់យោបល់ និងគំនិតចេញពីមូលដ្ឋានដោយផ្ទាល់ ជាគំនិតដ៏ប្រសើរជាងការដាក់គំនិតរបស់យើង ទៅក្នុងគម្រោងដោយមិនមានការពិគ្រោះយោបល់ជាមួយពួកគាត់ ព្រោះយោបល់/គំនិតដែលបានពីមូល ដ្ឋានអាចធ្វើឲ្យមានការចូលរួមពីសហគមន៍បានល្អ មានការដឹកនាំល្អ និងឈានទៅរកភាពជោគជ័យនា ថ្ងៃអនាគតផងដែរ ។
- ការធ្វើផែនការ និងគោលការណ៍ណែនាំច្បាស់លាស់ នាំទៅដល់កិច្ចសហការ និងសម្របសម្រួលពីភាគី ទីបី (អាជ្ញាធរមូលដ្ឋាន) ដោយរលូន។

ធ្វើនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥

អ្នកធ្វើរបាយការណ៍

**ម៉ែន វណ្ណារា**

## សកម្មភាពក្នុងវគ្គបណ្តុះបណ្តាល និងចុះសម្ភាសន៍តាមភូមិគោលដៅ








